# ព្រះរាជក្រឹត្យ

នស/រកត/០៩០៦/៣៤៩

## ស្តីពី

## ការបង្កើតគណៈឆ្មបកម្ពុជា

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

## ខេមរាជនា សម្ភូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៧៩/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដោយបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦

## ត្រាស់បង្គាប់

Downloaded from http://www.khmerlaws.com

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតគណៈឆ្មបមួយ ដើម្បីប្រមូលផ្ដុំឆ្មបទាំងអស់ដែលមាននីតិសម្បទាគ្រប់គ្រាន់អាចប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ និង អមវេជ្ជសាស្ត្រនៅព្រះរាជាណាចក្រកម្ពុជា ។

ពាក្យថាឆ្មបក្នុងព្រះរាជក្រឹត្យនេះគឺ នីតិជនដែលមានសញ្ញាប័ត្រឆ្មបចេញដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឬសញ្ញាប័ត្រឆ្មបចេញដោយគ្រឹះស្ថានសិក្សាដែលបានទទួលស្គាល់គុណភាពអប់រំដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។

ឆ្មបទាំងអស់ដែលប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ត្រូវសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មប ។

ចំពោះឆ្មបបុរាណក្រសួងសុខាភិបាលមានគោលនយោបាយដោយឡែក ។

## ជំពូកទី២

## បេសកកម្មរបស់គណៈឆ្មប

**មាត្រា ២.-**

គណៈឆ្មប ត្រូវឃ្លាំមើលការប្រព្រឹត្តទៅនៃបណ្ដាគោលការណ៍សីលធម៌ ភាពសុចរិត យុត្តិធម៌ និងភក្ដីភាពចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រឱ្យបានគង់វង្ស និងមានប្រសិទ្ធភាព ។

គណៈឆ្មប ត្រូវឃ្លាំមើលការប្រតិបត្តិរបស់សមាជិកខ្លួនទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងក្រមសីលធម៌ឆ្មប ។

គណៈឆ្មប ធានាការពារកិត្តិយស និង ឥស្សរភាពរបស់វិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ។

គណៈឆ្មប បំពេញភារកិច្ចរបស់ខ្លួនតាមរយៈក្រុមប្រឹក្សាគណៈឆ្មប ខេត្ត ក្រុង ដែលសរសេរកាត់ថា **ក.ឆ.ខ.** ក្រុមប្រឹក្សាគណៈឆ្មបភូមិភាគ ដែលសរសេរកាត់ថា **ក.ឆ.ភ.** និង ក្រុមប្រឹក្សាគណៈឆ្មបជាតិ ដែលសរសេរ កាត់ថា **ក.ឆ.ជ.** ។

## ផ្នែកទី ១

## តួនាទីសីលធម៌

**មាត្រា ៣.-**

គណៈឆ្មបមានបន្ទុករៀបរៀងក្រមសីលធម៌ឆ្មប យកលំនាំតាមលក្ខណៈចាំបាច់នៃវិជ្ជាជីវៈក្នុងការវិវត្តន៍ខ្ជាប់ខ្ជួនខាងបច្ចេកទេសសេដ្ឋកិច្ច និងសង្គមកិច្ចដែលត្រូវធ្វើឱ្យវិវត្តន៍ល្អក្នុងផលប្រយោជន៍របស់អ្នកជំងឺ ។

គណៈឆ្មបតាមឃ្លាំមើលរាល់ការប្រតិបត្តិកិច្ចការ សេចក្ដីគោរពប្រណិបត្តិ ។

គណៈឆ្មបជាអង្គការស្វយ័ត ។ ការចំណាយ ការផ្គត់ផ្គង់ប្រាក់កាស ម្ចាស់ការខ្លួនឯង ធានាឥស្សរភាពការពារផលប្រយោជន៍សីលធម៌វិជ្ជាជីវៈ ។

Downloaded from http://www.khmerlaws.com

## ផ្នែកទី ២

## តួនាទីគ្រប់គ្រងរដ្ឋបាល

**មាត្រា ៤.-**

ការចាត់ចែងអំណាចត្រូវអនុលោមតាមបញ្ជាគណៈឆ្មប ។

គណៈឆ្មបត្រូវរៀបចំធ្វើ និង ថែរក្សាទុកជាប្រចាំនូវបញ្ជីរាយនាមឆ្មប ដែលបានចុះឈ្មោះបំពេញលក្ខខណ្ឌច្បាប់ និងសីលធម៌ចាំបាច់ ។

កាតព្វកិច្ចនៃការចុះឈ្មោះ ក្នុងបញ្ជីរាយនាមឆ្មប គឺដើម្បីបំពេញការរៀបចំថែទាំព្យាបាលជំងឺ ។

គណៈឆ្មបជាអង្គការវិជ្ជាជីវៈតែមួយគត់ ដែលមានមុខងារតាមឃ្លាំមើលលក្ខខណ្ឌនៃការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនេះ ។

## ផ្នែកទី ៣

## តួនាទីសម្រេចសេចក្តីតាមបែបតុលាការ

**មាត្រា ៥.-**

បណ្តឹងអំពីការប្រព្រឹត្តខុសឆ្គងនៃមុខវិជ្ជាជីវៈរបស់ឆ្មបណាមួយទៅគណៈឆ្មប មិនមែនជាឧបសគ្គក្នុងការធ្វើបណ្តឹងចំពោះការប្រព្រឹត្តខុសឆ្គងនេះ ទៅតុលាការឡើយ ។

## ផ្នែកទី ៤

## តួនាទីពិគ្រោះផ្តល់យោបល់

**មាត្រា ៦.-**

គណៈឆ្មបអាចត្រូវបានកោះហៅឱ្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិជ្ជាជីវៈឆ្មបទាំងឡាយ។

## ផ្នែកទី៥

## តួនាទីជួយសង្គ្រោះគ្នាទៅវិញទៅមក

**មាត្រា ៧.-**

ការជួយសង្គ្រោះគ្នាទៅវិញទៅមកនេះមានបច្ច័យដល់ឆ្មប និងគ្រួសាររបស់គេ ។ ការជួយសង្គ្រោះគ្នាបានរៀបចំតាមបែបបទដូចតទៅ ÷

- គណៈឆ្មបត្រូវមានក្នុងថវិការបស់ខ្លួន ប្រាក់បម្រុងសម្រាប់ជួយសង្គ្រោះគ្នាទៅវិញទៅមក ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់ប្រាក់បម្រុងជាជំនួយភ្លាមៗ ក្នុងករណីសមរម្យដល់គ្រួសារឆ្មប ដែលត្រូវរងទុក្ខលំបាក
- គណៈឆ្មបត្រូវមានគណៈកម្មការមួយជួយសង្គ្រោះគ្នាទៅវិញទៅមក ដែលមានតំណាងសមាគមឆ្មបកម្ពុជាម្នាក់ជាសមាជិក
- គណៈកម្មការនេះ ចាត់ចែងឱ្យមានធនធានប្រចាំឆ្នាំ ដែលកាត់យកខ្លះពីប្រាក់វិភាគទានពីឆ្មប

Downloaded from http://www.khmerlaws.com

ម្នាក់ៗដែលចុះឈ្មោះ ក្នុងគណៈឆ្មប ។

## ជំពូកទី ៣

## រចនាសម្ព័ន្ធ

## ផ្នែកទី១

## ក្រុមប្រឹក្សាគណៈឆ្មបថ្នាក់ខេត្ត ក្រុង (ក.ឆ.ខ.)

**មាត្រា ៨.-**

ក.ឆ.ខ. ត្រូវបង្កើតនៅតាមខេត្ត ក្រុងនីមួយៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំពោះខេត្ត ក្រុង ដែលមានចំនួនឆ្មបតិចជាងម្ភៃ (២០)នាក់ ត្រូវបញ្ចូលទៅខេត្តដែលនៅជិតជាងគេដើម្បីបង្កើតក្រុមប្រឹក្សាគណៈឆ្មប ។

**មាត្រា ៩.-**

ក.ឆ.ខ. ត្រូវមានសមាជិកពេញសិទ្ធិចំនួនប្រាំបួន (០៩)រូប និងសមាជិកជំនួសចំនួនប្រាំបួន(០៩)រូប ក្នុងករណីដែលចំនួនឆ្មបដែលបានចុះឈ្មោះក្នុងបញ្ជីមានមិនលើសពីមួយរយ (១០០) នាក់ ។ ចំនួននេះនឹងឡើងទៅដល់ដប់មួយ (១១), ដប់ប្រាំ (១៥), ដប់ប្រាំបួន(១៩) ឬ ម្ភៃមួយ (២១)រូប បើសិនចំនួនឆ្មបនៅក្នុងបញ្ជីមានលើសពីមួយរយ(១០០), ប្រាំរយ(៥០០), មួយពាន់ (១.០០០) ឬ ពីរពាន់(២.០០០) នាក់ ។

**មាត្រា ១០.-**

ក.ឆ.ខ. ត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងអង្គមហាសន្និបាត ដោយបណ្តាឆ្មបដែលបានចុះឈ្មោះ នៅក្នុងបញ្ជីរបស់ ក.ឆ.ខ. សម្រាប់រយៈពេលប្រាំមួយ (០៦)ឆ្នាំ ។

សមាជិកចប់អាណត្តិ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សា ធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួននៅក្នុងរយៈពេលពីរ (០២)ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន ១/៣ នៃសមាជិកក្រុមប្រឹក្សា ។ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ក្នុងករណីដែលចំនួនសមាជិកផ្លាស់ប្តូរមានចំនួនចែកមិនដាច់ ។

សមាសភាពការិយាល័យរបស់ក.ឆ.ខ. រួមមាន ប្រធានក្រុមប្រឹក្សាមួយរូបអនុប្រធានមួយ (០១) រូបអគ្គលេខាធិការ មួយ (០១ )រូប ហិរញ្ញិកមួយ (០១ )រូប និងសមាជិកប្រាំ (០៥ )រូប ។

**មាត្រា ១១.-**

ក.ឆ.ខ. បំពេញការងារនៅក្នុងក្របខ័ណ្ឌខេត្ត ក្រុងរបស់ខ្លួន និង ក្រោមការត្រួតពិនិត្យរបស់គណៈឆ្មបជាតិ ចំពោះសមត្ថកិច្ចទូទៅទាំងឡាយ ដែលមានចែងក្នុងមាត្រា២ នៃព្រះរាជក្រឹត្យនេះ។ ក.ឆ.ខ. សម្រេចអារកាត់ក្នុងការចុះឈ្មោះឆ្មបដែលបានបំពេញល័ក្ខខ័ណ្ឌតាម មាត្រា៣ ជំពូកទី១ និង មាត្រា៦ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ នៅក្នុង

Downloaded from http://www.khmerlaws.com

បញ្ជីរបស់គណៈឆ្មប ។ គ.ឆ.ខ. មិនប្រកាន់ភេទ ជំនឿសាសនា និន្នាការនយោបាយ ឋានៈសង្គម ធនធាន ឬ ស្ថានភាព ឯទៀតរបស់សមាជិកខ្លួនឡើយ ។

**មាត្រា ១២.-**

គ.ឆ.ខ. ពុំមានអំណាចដាក់វិន័យទេ បើមានពាក្យប្តឹងចំពោះឆ្មបដែលស្ថិតក្រោម សមត្ថកិច្ចរបស់ខ្លួន គ.ឆ.ខ. ត្រូវបញ្ជូនបណ្តឹងនោះទៅក្រុមប្រឹក្សាគណៈឆ្មបភូមិភាគ ដោយបញ្ជាក់ហេតុផលច្បាស់លាស់ ។

**មាត្រា ១៣.-**

ប្រធានតំណាងឱ្យ គ.ឆ.ខ. នៅក្នុងគ្រប់សកម្មភាពស៊ីវិល ។

**មាត្រា ១៤.-**

ការប្រជុំនៃក្រុមប្រឹក្សាគណៈឆ្មបខេត្ត ក្រុង នឹងមិនធ្វើជាសាធារណៈឡើយ ។ កាលណាមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានមានឧត្តមានុភាពសម្រេច ។ ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ត្រូវបានអញ្ជើញចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា គ្រាន់តែមានសម្លេងពិគ្រោះយោបល់ ។ គ.ឆ.ខ. អាចអញ្ជើញទីប្រឹក្សាច្បាប់មួយរូបចូលរួមក្នុងអង្គប្រជុំ ។

**មាត្រា ១៥.-**

ឆ្មបនៅតាមបណ្តាខេត្ត ក្រុង ត្រូវដាក់ពាក្យសុំចុះឈ្មោះនៅក្នុងបញ្ជី ដែលកាន់កាប់ជាប្រចាំដោយក្រុមប្រឹក្សាគណៈឆ្មបខេត្ត ក្រុងពាក់ព័ន្ធ ។ អាចចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មប តែចំពោះឆ្មបដែលមានសញ្ញាប័ត្រឆ្មប ចេញដោយក្រសួងសុខាភិបាលឬសញ្ញាប័ត្រចេញដោយគ្រឹះស្ថានសិក្សា ដែលទទួលស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ក្នុងការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង បានបំពេញល័ក្ខខ័ណ្ឌច្បាប់ និង ក្រមសីលធម៌ដែលបានកំណត់ ។

ឆ្មបអាចចុះឈ្មោះបានតែនៅក្នុងបញ្ជីនៃខេត្ត ក្រុងដែលជាកន្លែងប្រកបវិជ្ជាជីវៈរបស់ខ្លួនតែប៉ុណ្ណោះ ។

**មាត្រា ១៦.-**

គ.ឆ.ខ. ត្រូវសម្រេចលើការសុំចុះឈ្មោះក្នុងរយៈពេលយ៉ាងយូរបី(០៣)ខែ ដោយគិតចាប់តាំងពីថ្ងៃទទួលពាក្យដែលមានឯកសារគ្រប់គ្រាន់ ។

ក្នុងរយៈពេលមួយសប្តាហ៍យ៉ាងយូរក្រោយការសម្រេច ក្រុមប្រឹក្សាត្រូវជូនដំណឹងតាមលិខិតអនុសាសន៍ទៅឆ្មបសាមី ។ បើមានការបដិសេធលើសំណើរសុំចុះឈ្មោះ គ.ឆ.ខ. ត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ។

ការអនុញ្ញាតឱ្យចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មបខេត្ត ក្រុងនីមួយៗ ត្រូវជូនដំណឹងយ៉ាងយូរពីរសប្តាហ៍ទៅអាជ្ញាធរ ខេត្ត ក្រុង ទៅព្រះរាជអាជ្ញានៃខេត្ត ក្រុងពាក់ព័ន្ធ និង ទៅក្រុមប្រឹក្សាគណៈឆ្មបជាតិ ។

**មាត្រា ១៧.-**

ក្រោយពីបានអនុញ្ញាតឱ្យចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មបខេត្ត ក្រុង ដែលខ្លួនកំពុងប្រកបវិជ្ជាជីវៈ

Downloaded from http://www.khmerlaws.com

ឆ្មបអាចប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនៅខេត្ត ក្រុងដែលខ្លួនបានចុះឈ្មោះប៉ុណ្ណោះ ។ ក្នុងករណីមានការផ្លាស់ប្តូរលំនៅស្ថានវិជ្ជាជីវៈទៅក្រៅខេត្ត ក្រុង ដែលខ្លួនបានសុំចុះឈ្មោះ ឆ្មបត្រូវជូនដំណឹងទៅក្រុមប្រឹក្សាចាស់ និងត្រូវធ្វើពាក្យសុំចុះឈ្មោះសារជាថ្មី ទៅក្រុមប្រឹក្សាខេត្ត ក្រុងដែលខ្លួនទៅរស់នៅប្រកបវិជ្ជាជីវៈ ។

**មាត្រា ១៨.-**

ក្រុមប្រឹក្សាគណៈឆ្មបខេត្ត ក្រុង ត្រូវទទួលបណ្តឹងជំទាស់ពីក្រុមប្រឹក្សាជាតិ សមាគមឆ្មប រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ព្រះរាជអាជ្ញាអមតុលាការ ឬឆ្មបណាម្នាក់ ដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មប រួចហើយធ្វើរបាយការណ៍ផ្ញើជូនគណៈឆ្មបជាតិ ។

## ផ្នែកទី២

## ក្រុមប្រឹក្សាគណៈឆ្មបភូមិភាគ (ក.ឆ.ភ.)

**មាត្រា ១៩.-**

ការបែងចែកភូមិភាគសម្រាប់គណៈឆ្មបកម្ពុជានេះ ត្រូវបានរៀបចំដូចខាងក្រោម ÷

ភូមិភាគ ១ : រួមមានរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង មានទីតាំងនៅរាជធានីភ្នំពេញ ។

ភូមិភាគ ២ : មានខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន មានទីតាំងនៅខេត្តបាត់ដំបង ។

ភូមិភាគ ៣ : មានខេត្តតាកែវ កំពត កោះកុង ក្រុងព្រះសីហនុ និងក្រុងកែប មានទីតាំងនៅខេត្តកំពត ។

ភូមិភាគ ៤ : មានខេត្តស្ទឹងត្រែង រតនះគិរី មណ្ឌលគិរី ក្រចេះ និងព្រះវិហារ មានទីតាំងនៅខេត្តស្ទឹងត្រែង ។

ភូមិភាគ ៥ : មានខេត្តកំពង់ចាម កំពង់ធំ ព្រៃវែង ស្វាយរៀង មានទីតាំងនៅខេត្តកំពង់ចាម ។

**មាត្រា ២០.-**

**ក.ឆ.ភ.** មានតួនាទីជាក្រុមប្រឹក្សាវិន័យវិជ្ជាជីវៈថ្នាក់បឋម មានសមាជិកពេញសិទ្ធិ ចំនួនប្រាំបួន (០៩)រូប និង សមាជិកជំនួសចំនួនប្រាំបួន (០៩) រូប បោះឆ្នោតជ្រើសរើសក្នុងចំណោម **ក.ឆ.ខ.** ក្នុងភូមិភាគ។ **ក.ឆ.ខ.** នីមួយៗ ត្រូវជ្រើសរើសតំណាងរបស់ខ្លួនឱ្យបានយ៉ាងតិចមួយ (០១) រូបពេញសិទ្ធិ និងមួយ (០១) រូបជាជំនួស ចំនួនអាសនៈដែលនៅសល់ ត្រូវបែងចែកទៅខេត្ត ក្រុង ដោយផ្អែកទៅលើចំនួនឆ្មប ដែលបានចុះឈ្មោះជាសមាជិកក្រុមប្រឹក្សាភូមិភាគ ។សមាជិកក្រុមប្រឹក្សាភូមិភាគ ត្រូវបានបោះឆ្នោតជ្រើសរើសសម្រាប់រយៈពេល ០៦ឆ្នាំ។

សមាជិកចប់អាណត្តិអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សា



Downloaded from http://www.khmerlaws.com

ធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងសមាសភាពនៃការិយាល័យ នៅក្នុងរយៈពេលពីរ (០២) ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន ១/៣ នៃសមាជិកក្រុមប្រឹក្សា ។ សមាជិកជំនួសត្រូវចូលជំនួយសមាជិកពេញសិទ្ធិ នៅពេលដែលសមាជិកនេះអវត្តមានដោយមូលហេតុអ្វីក៏ដោយ ។

ការិយាល័យមានសមាសភាព : ប្រធានមួយ (០១) រូប អនុប្រធានមួយ (០១) រូប អគ្គលេខាធិការមួយ (០១) រូប ហេរញ្ញិកមួយ (០១) រូប និង សមាជិកប្រាំ (០៥) រូប ។

**មាត្រា ២១.-**

ប្រធាន ក.ឆ.ខ. ប្រធាន ក.ឆ.ភ. និងអគ្គលេខាធិការនៃក្រុមប្រឹក្សាទាំងនេះមិនអាចកាន់មុខងារត្រួតគ្នាបានឡើយ ។

**មាត្រា ២២.-**

អង្គប្រជុំ ក.ឆ.ភ. ត្រូវបានចូលរួមក្នុងឋានៈជាអនុប្រធាន និងជាអ្នកពិគ្រោះយោបល់ដោយ ៖

-តំណាងឱ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល

-ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ដែលជាទីតាំងនៃក្រុមប្រឹក្សាភូមិភាគ

-ទីប្រឹក្សាច្បាប់មួយរូប ចាត់តាំងដោយប្រធានតុលាការនៃខេត្ត ក្រុងនោះ

-ឆ្មបការងារមួយរូប បើមានចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ។

**មាត្រា ២៣.-**

នៅក្នុងក្របខ័ណ្ឌគណៈឆ្មបភូមិភាគ ក.ឆ.ភ. អនុវត្តនីការងាររបស់ខ្លួនតែទៅលើសមត្ថកិច្ចខាងវិន័យតែប៉ុណ្ណោះ ។

ក.ឆ.ភ. អាចទទួលពាក្យប្តឹងជំទាស់ពី ក.ឆ.ជ. ក.ឆ.ខ. សមាគមឆ្មប រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាល អាជ្ញាធរខេត្ត ក្រុង ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង ឬ សាមីឆ្មប ដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មប ។

ក.ឆ.ភ. ត្រូវពិនិត្យសម្រេចនៅក្នុងរយៈពេលប្រាំមួយ (០៦) ខែយ៉ាងយូរ ក្រោយបានទទួលពាក្យប្តឹង ។ បើមិន ដូច្នេះទេ ក.ឆ.ជ. អាចបញ្ជូនពាក្យប្តឹងនេះទៅ ក.ឆ.ភ. ណាមួយផ្សេងទៀតដែលបានជ្រើសរើស ។

**មាត្រា ២៤.-**

ឆ្មបដែលកំពុងបម្រើការនៅក្នុងសេវាសាធារណៈ ហើយបានសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈឆ្មបនឹងអាចបកស្រាយចំពោះមុខ ក.ឆ.ភ. បានចំពោះសកម្មភាពក្នុងមុខងារសាធារណៈរបស់ខ្លួន តែតាមរយៈរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមរយៈប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ឬ តាមរយៈព្រះរាជអាជ្ញាអមតុលាការតែប៉ុណ្ណោះ ។

**មាត្រា ២៥.-**

ការដាក់វិន័យត្រូវធ្វើឡើងនៅចំពោះមុខឆ្មបសាមី ។ ឆ្មបសាមីអាចមានអ្នកការពារដែលជាឆ្មប

Downloaded from http://www.khmerlaws.com

ឬ ជាមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ បើឆ្មបសាមីមិនព្រមចូលខ្លួនមកបំភ្លឺ គ.ឆ.គ. តាមការអញ្ជើញចំនួន បី (០៣) លើក ដោយគ្មានមូលហេតុច្បាស់លាស់ គ.ឆ.គ. នឹងអនុវត្តតាមចំណុចទី៤ ក្នុងមាត្រា២៧ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ២៦.-**

គ.ឆ.គ. ត្រូវមានបញ្ជីកត់ត្រានូវរាល់ការប្រជុំដាក់វិន័យ ។ គ.ឆ.គ. ត្រូវធ្វើកំណត់ហេតុត្រឹមត្រូវ ដោយមានការបញ្ជាក់ និងចុះហត្ថលេខាពីគ្រប់សមាជិកទាំងអស់នៃក្រុមប្រឹក្សា ព្រមទាំងហត្ថលេខារបស់សាមីជន ដែលត្រូវចោទសួរនោះផង ។

**មាត្រា ២៧.-**

គ.ឆ.គ. ដោយមានការចូលរួមពីផ្នែកវិន័យនៃគ.ឆ.ជ. អាចដាក់វិន័យដល់សមាជិកដូចខាងក្រោម÷

១- ការព្រមាន។

២-សេចក្តីបន្ទោសដោយកត់ទុកនៅក្នុងឯកសារផ្ទាល់ខ្លួន។

៣-ហាមប្រកបវិជ្ជាជីវៈមួយរយៈពេលមិនលើសពីបី (០៣) ឆ្នាំ ឬ ជាអចិន្ត្រៃយ៍ក្នុងផ្នែកណាមួយ ឬ ជាទូទៅ នៃមុខងារវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រដែលរដ្ឋទទួលស្គាល់ ។

៤-ការលុបឈ្មោះចេញពីបញ្ជីគណៈឆ្មប។

ឆ្មបដែលត្រូវលុបឈ្មោះចេញពីក្នុងបញ្ជីគណៈឆ្មប មិនអាចសុំចុះឈ្មោះនៅកន្លែងណាផ្សេងទៀតបានឡើយ ។

សេចក្តីដែលបានសម្រេចចុងក្រោយដែលបានលើកឡើង ត្រូវតែផ្សព្វផ្សាយទៅគ្រប់ គ.ឆ.ខ. ព្រមទាំងទៅ គ.ឆ.ជ. ។ ការសម្រេចរបស់ គ.ឆ.គ. ត្រូវតែមានហេតុផលច្បាស់លាស់។

**មាត្រា ២៨.-**

ក្រោយបានទទួលវិន័យហាមប្រកបវិជ្ជាជីវៈអស់រយៈកាលបី (០៣) ឆ្នាំយ៉ាងតិចមក ឆ្មបដែលទទួលវិន័យ អាចទទួលការលើកលែងវិន័យពីក្រុមប្រឹក្សាគណៈឆ្មប ដែលបានដាក់វិន័យដល់ខ្លួន ។ ការសុំលើកលែងវិន័យនេះត្រូវធ្វើឡើងដោយឆ្មបសាមី ។ កាលណាលិខិតស្នើសុំលើកលែងវិន័យនេះ ត្រូវបានបដិសេធក្រោយពីបានធ្វើការពិនិត្យពិចារណាស៊ីជម្រៅមក ការស្នើសុំលើកលែងវិន័យសារជាថ្មី នឹងអាចធ្វើទៅបានតែក្នុងរយៈកាល មួយ (០១) ឆ្នាំ ទៅមុខទៀត ។

ចំពោះវិន័យអចិន្ត្រៃយ៍ក្នុងផ្នែកណាមួយ ឬ ជាទូទៅនៃមុខងារវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ដែលរដ្ឋទទួលស្គាល់ មិនអាចស្នើសុំលើកលែងបានទេ។

**មាត្រា ២៩.-**

ការអនុវត្តវិន័យរបស់ឆ្មប មិនមែនជាឧបសគ្គរាំងដល់ការអនុវត្តការដាក់វិន័យខាងរដ្ឋបាល ឬ តុលាការឡើយ ។

Downloaded from http://www.khmerlaws.com

## ផ្នែកទី៣

## ក្រុមប្រឹក្សាគណៈឆ្មបជាតិ (ក.ឆ.ជ.)

**មាត្រា ៣០.-**

ក.ឆ.ជ. ត្រូវបានជ្រើសរើសតាមការបោះឆ្នោតសម្រាប់រយៈពេលប្រាំមួយ(០៦)ឆ្នាំ បែងចែកដូចខាងក្រោម ÷

-តំណាងឱ្យខេត្ត ក្រុង នីមួយៗ ចំនួនមួយ (០១) រូប ជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមសមាជិកគណៈឆ្មប ខេត្ត ក្រុងនោះ អ្នកជាប់ឆ្នោតត្រូវបានតែងតាំងដោយប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង

-តំណាងឱ្យរាជធានីភ្នំពេញចំនួនពីរ (០២) រូប ជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមសមាជិកគណៈឆ្មបរាជធានីភ្នំពេញ ។ អ្នកជាប់ឆ្នោតត្រូវបានតែងតាំង ដោយប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ

- តំណាងឱ្យអង្គភាពថ្នាក់កណ្តាលចំនួនប្រាំ (០៥) រូប ជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោម សមាជិកឆ្មបថ្នាក់កណ្តាល និងបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល

-តំណាងឱ្យសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រចំនួនមួយ(០១)រូប ជ្រើសរើសដោយការបោះឆ្នោត តែងតាំងដោយសាកលវិទ្យាធិការ ។

**មាត្រា ៣១.-**

ក.ឆ.ជ. ត្រូវធ្វើការជ្រើសរើសផ្លាស់ប្តូរសមាជិកចំនួនមួយភាគបី (១/៣) ក្នុងរយៈពេលពីរ (០២) ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរសមាជិកមួយភាគបី (១/៣) ម្តងៗ ក្រុមប្រឹក្សាគណៈឆ្មបជាតិ ត្រូវធ្វើការជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួនសម្រាប់ពីរ (០២) ឆ្នាំម្តង ។

ការិយាល័យរបស់ក្រុមប្រឹក្សាគណៈឆ្មបជាតិកម្ពុជា រួមមាន : ប្រធានក្រុមប្រឹក្សាមួយ (០១)រូប អនុប្រធានចំនួនពីរ (០២)រូប អគ្គលេខាធិការមួយ (០១)រូប អគ្គលេខាធិការរងមួយ(០១)រូប ហិរញ្ញិក មួយ (០១)រូប និងហេរញ្ញិករងមួយ (០១) រូប ។ ប្រធាន និង សមាជិក **ក.ឆ.ជ.** ដែលចេញពីតំណែងអាចឈរឈ្មោះឱ្យគេជ្រើសរើសសារជាថ្មីបាន ។

**មាត្រា ៣២.-**

ក.ឆ.ជ. មានជំនួយការជាឆ្មប ចំនួនពីរ (០២) រូប តំណាងឱ្យ រដ្ឋមន្ត្រីក្រសួងសុខាភិបាល មួយ (០១)រូប និងតំណាងឱ្យរដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈមួយ (០១) រូប មានសម្លេងពិគ្រោះយោបល់ ។

**មាត្រា ៣៣.-**

ក.ឆ.ជ. មានផ្នែកវិន័យមួយដែលមានសមាជិក(០៧)រូប ដឹកនាំដោយប្រធានមួយ (០១) រូប ជ្រើសតាំងក្នុងចំណោមសមាជិកប្រាំពីរ (០៧) រូបនេះ ។ សមាជិកផ្នែកវិន័យ ត្រូវបានជ្រើសរើសតាមការបោះឆ្នោត ក្នុងចំណោមសមាជិកការិយាល័យនៃក្រុមប្រឹក្សា ក.ឆ.ជ. ។

Downloaded from http://www.khmerlaws.com

ផ្នែកវិន័យមានភារកិច្ចដូចបានកំណត់ក្នុងមាត្រា ២៣ និងមាត្រា ២៧ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣៤.-**

បន្ទាប់ពីបានធ្វើការផ្លាស់ប្តូរសមាជិកចំនួនមួយភាគបី ១/៣ របស់ខ្លួន **គ.ឆ.ជ.** ត្រូវធ្វើការជ្រើសតាំងផ្នែកវិន័យសារជាថ្មី។

**មាត្រា ៣៥.-**

**គ.ឆ.ជ.** បំពេញតួនាទីថ្នាក់ជាតិរបស់ខ្លួន ពេលបំពេញបេសកកម្ម ដូចមានចែងនៅក្នុងមាត្រា ២ នៃព្រះរាជក្រឹត្យនេះ ។

**គ.ឆ.ជ.** ឃ្លាំមើលជាអាទិ៍ ការគោរពអនុវត្តតាម របស់សមាជិកនៃគណៈឆ្មបទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈ និងគោលការណ៍ទាំងឡាយដែលបានកំណត់នៅក្នុងក្រមសីលធម៌ឆ្មប។

**គ.ឆ.ជ.** សហការជាមួយ **គ.ឆ.ខ.** ធ្វើការសិក្សាដោះស្រាយនូវបញ្ហាស្មុគស្មាញទាំងឡាយដែលពាក់ព័ន្ធទៅនឹងប្រព្រឹត្តកម្មវិជ្ជាជីវៈរបស់ឆ្មប ។

**គ.ឆ.ជ.** បំពេញការងារនេះតាមរយៈផ្នែក និងគណៈកម្មការទាំងឡាយរបស់ខ្លួន និងពិនិត្យសិក្សានូវបណ្តាបញ្ហា ឬ គម្រោងការណ៍ទាំងឡាយដែលបានលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ ។

**មាត្រា ៣៦ .-**

**គ.ឆ.ជ.** ត្រូវកំណត់អំពីចំនួនទឹកប្រាក់វិភាគទានឯកភាពមួយ ដែលសមាជិកម្នាក់ៗត្រូវបង់នៅពេលសុំចុះឈ្មោះ និងត្រូវបង់ប្រចាំឆ្នាំ ។

**គ.ឆ.ជ.** ត្រូវកម្រិតផងដែរ នូវចំនួនវិភាគទានដែល **គ.ឆ.ខ.** ត្រូវបង់ជូនទៅ **គ.ឆ.ជ.** ទៅ **គ.ឆ.គ.** និង ត្រូវរក្សាទុកនៅក្នុង **គ.ឆ.ខ.** ដើម្បីធានាចំណាយក្នុងការបំពេញការងារជាទូទៅ ។ ការបង់វិភាគទានគឺជាកាតព្វកិច្ច របស់សមាជិកម្នាក់ៗ ។

**គ.ឆ.ជ.** គ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់របស់គណៈឆ្មប និងអាចបង្កើត ឬ ឧបត្ថម្ភដល់វណ្ណកម្មទាំងឡាយ ដែលជាផលប្រយោជន៍នៃវិជ្ជាជីវៈឆ្មប ព្រមទាំងការងារសង្គ្រោះផ្សេងៗ ។

**គ.ឆ.ជ.** ត្រួតពិនិត្យការគ្រប់គ្រងរបស់**គ.ឆ.ខ.**និង**គ.ឆ.គ.**។ **គ.ឆ.ខ.** ត្រូវរាយការណ៍ជូន**គ.ឆ.ជ.** ជាមុន និងចម្លងជូនទៅ **គ.ឆ.គ.** ចំពោះការបង្កើតអង្គការទាំងឡាយរបស់ខ្លួន ព្រមទាំងការចាត់ចែងរបស់អង្គការទាំងនោះ ។

**មាត្រា ៣៧.-**

**គ.ឆ.ជ.** ត្រូវបង្កើតគណៈកម្មការសម្រាប់ចាត់ចែងហិរញ្ញវត្ថុ និងធ្វើសវនកម្មផ្ទៃក្នុង។ សមាជិកនៃ គណៈកម្មការនេះត្រូវជ្រើសរើសដោយ **គ.ឆ.ជ.** ក្នុងចំណោមសមាជិកដែលមិនស្ថិតនៅក្នុងការិយាល័យ នៃ ក្រុមប្រឹក្សា និងផ្នែកវិន័យ។

Downloaded from http://www.khmerlaws.com

ក្នុងបំណាច់ឆ្នាំនីមួយៗ គណៈកម្មការនេះ ត្រូវធ្វើរបាយការណ៍អំពីការត្រួតពិនិត្យរបស់ខ្លួនជូន ក.ឆ.ជ. ។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៨.-**

ក្នុងអាណត្តិទី ១ នេះ សមាសភាព ក.ឆ.ជ. ត្រូវបានជ្រើសតាំង និងឯកភាពដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ដើម្បីដំណើរការឱ្យមានប្រសិទ្ធភាព ។

ក្នុងអំឡុងពេលប្រាំមួយ ( ០៦ ) ឆ្នាំដំបូងនៃអាណត្តិទី ១ សមាសភាពការិយាល័យរបស់ក.ឆ.ខ. ក.ឆ.ក. ត្រូវបានជ្រើសតាំងដោយសហភាគរៈរបស់ខ្លួន និងទទួលស្គាល់ដោយ ក.ឆ.ជ. ។

**មាត្រា ៣៩.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវតែងតាំងក្រុមការងារមួយជាបណ្តោះអាសន្នដើម្បីរៀបចំដំណើរការបង្កើតគណៈឆ្មបកម្ពុជា ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ៤០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤១.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០០៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាសបន្ទាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣.ស.០៦០៩.៤១៣

លេខ : ៣៧០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សួន ជីនកេន**

Downloaded from http://www.khmerlaws.com